ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០២

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

**Work Activities**

ប្រចាំខែកុម្ភៈ ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | កិច្ចប្រជុំផ្ទៃក្នុងលើសេចក្តីព្រាងនៃសេចក្តីព្រាងច្បាប់ស្តីពីអង្គការតុលាការ និង សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ២ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែមករា ឆ្នាំ២០១៤ | ៤ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១០ |

# សេចក្តីព្រាងនៃសេចក្តីព្រាងច្បាប់ស្តីពីអង្គការតុលាការ និងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

បន្ទាប់ពីបានទទួលលិខិតពីអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង ដើម្បីពិនិត្យលើ**សេចក្តីព្រាងនៃសេចក្តីព្រាងច្បាប់ស្តីពីអង្គការតុលាការ និងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម** ក្នុងខែកុម្ភៈ ឆ្នាំ២០១៤។

ឯកឧត្តម ឃឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមប្រឹក្សា សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានចាត់តាំង ឯកឧត្តម ឌុយ ផៅ អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដឹកនាំកិច្ចប្រជុំផ្ទៃក្នុងនេះ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក សមាជិកា ECOSOCC មួយចំនួននៃក្រុមទាំងបី គឺក្រុមទី១ មាន **ឯកឧត្តម កែវ វិចិត្រ ឯកឧត្តម លី គឹមសុខ លោកជំទាវ ស៊ុន សុគន្ធមាលា** និង **ឯកឧត្តម ឥន យឿន** ក្រុមទី២ មាន **លោកជំទាវ គាល់ ណៃអ៊ីម ឯកឧត្តម អ៊ុំ កុសល** និង **ឯកឧត្តម អ៊ុច ថោងសេង** និងក្រុមទី៣ មាន **ឯកឧត្តម ឌី សុខណាត** និង **ឯកឧត្តម ប៉ែន សារឿន** សរុបទាំងអស់មានសមាសភាព ១១រូប។

សេចក្តីព្រាងច្បាប់ស្តីពីអង្គការតុលាការ និងសេចក្តីព្រាងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រៀបចំឡើងដោយក្រសួងយុត្តិធម៌។ ក្រសួងយុត្តធម៌បានដាក់សេចក្តីព្រាងច្បាប់ទាំងពីរនេះឆ្លងកិច្ចប្រជុំឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងឆ្លងកិច្ចប្រជុំអន្តរក្រសួង ចប់សព្វគ្រប់។

១-សេចក្តីព្រាងច្បាប់ស្តីពីអង្គការតុលាការនេះ មានគោលបំណងធានាឯករាជ្យភាពនៃអំណាចតុលាការ ធានារក្សាអនាគត និងការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ធានាឲ្យមានកិច្ចដំណើរការល្អរបស់អង្គការតុលាការ និងអង្គការអយ្យការ លើកកម្ពស់សេវាសាធារណៈឲ្យមានប្រសិទ្ធភាពនិងឆាប់រហ័ស និងធានាក្នុងការ ផ្តល់ភាពយុត្តិធម៌លើរឿងក្តីគ្រប់ប្រភេទ ដើម្បីបង្កើនជំនឿទុកចិត្តពីប្រជាពលរដ្ឋ និងរួមចំណែកពង្រឹង សុវត្ថិភាពសង្គម។ សេចក្តីព្រាងច្បាប់ស្តីពីអង្គការតុលាការនេះ មានគោលដៅកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គការតុលាការគ្រប់ផ្នែកនិងគ្រប់ជាន់ថ្នាក់ ដែលជាសាលាជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា កំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់នៃព្រះរាជាណាចក្រកម្ពុជា កំណត់អំពីសមត្ថកិច្ចរបស់តុលាការគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់ទៅតាមជំនាញ និងរៀបចំការងារគ្រប់គ្រង ការងាររដ្ឋបាល និងដំណើរការប្រព្រឹត្តទៅរបស់តុលាការ។

២-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានគោលដៅបង្កើត និងកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ក្នុងគោលបំណងជួយព្រះមហាក្សត្រ ដើម្បីធានាឯករាជ្យភាពនៃអំណាចតុលាការ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ សេចក្តីព្រាងច្បាប់នេះ មានវិសាលភាពអនុវត្តទៅលើចៅក្រមនិងព្រះរាជអាជ្ញាទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែមានច្បាប់ដោយឡែកកំណត់ផ្សេងពីនេះ។

កិច្ចប្រជុំផ្ទៃក្នុងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ លើសេចក្តីព្រាងច្បាប់ទាំងពីរនេះ បានប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា នឹងត្រៀមជាយោបល់ ដើម្បីរាយការណ៍ជូន ឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃអង្គារ ទី០៤ ខែកុម្ភៈ ឆ្នាំ២០១៤ នៅវេលាម៉ោង ៩:០០នាទីព្រឹក នៅទីស្ដីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្ដម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្សនិស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ។

២- បញ្ហាផ្សេងៗ

២.១-សេចក្ដីព្រាងកិច្ចព្រមព្រៀងស្ដីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ របស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ និងពិធីសារ នៃធម្មនុញ្ញអាស៊ាន ស្ដីពីយន្តការដោះស្រាយជម្លោះ។

២.២-ពិធីសារស្ដីពីវិសោធកម្មលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមស្ដីពីការជំរុញនិងការការពារវិនិយោគ

២.៣- កិច្ចព្រមព្រៀងស្ដីពីគយ



ក្រោយពីបានពិនិត្យពិភាក្សា ផ្លាស់ប្ដូរយោបល់គ្នា អង្គប្រជុំបានសម្រេច ដូចខាងក្រោម៖

**១-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីអាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្សនិស្សិតតាមគ្រឹះស្ថានសិក្សាសាធារណៈ៖**

-ឯកភាពលើទម្រង់ ខ្លឹមសារនៃសេចក្ដីព្រាងអនុក្រឹត្យនេះ។ ដោយមើលឃើញសេចក្ដីព្រាងអនុក្រឹត្យនេះមានផលប៉ះពាល់ ឯកឧត្ដមឧបនាយករដ្ឋមន្ត្រី ស្នើឲ្យក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រុមRIAដែលស្ថិតនៅក្រោមECO-SOCC ដើម្បីសិក្សាផលប៉ះពាល់ក្នុងការចំណាយថវិការបស់រដ្ឋរវាងអនុក្រឹត្យចាស់និងអនុក្រឹត្យថ្មី រួចធ្វើកំណត់បង្ហាញជូនគណៈរដ្ឋមន្ត្រីដើម្បីពិនិត្យ និងសម្រេច។

២- បញ្ហាផ្សេងៗ

២.១-សេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ របស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ និងពិធីសារនៃធម្មនុញ្ញអាស៊ាន ស្តីពីយន្តការដោះស្រាយជម្លោះ

-អង្គប្រជុំបានឯកភាពលើទម្រង់ ខ្លឹមសារនៃសេចក្តីព្រាងកិច្ចព្រមព្រៀង ស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ និងពិធីសារនៃធម្មនុញ្ញអាស៊ាន ស្តីពីយន្តការដោះស្រាយជម្លោះ។(**របស់ក្រសួងការបរទេស**)

២.២-ពិធីសារស្តីពីវិសោធកម្មលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពីការជំរុញ និងការការពារវិនិយោគ

-អង្គប្រជុំបានឯកភាពលើទម្រង់ ខ្លឹមសារនៃពិធីសារស្តីពីវិសោធកម្មលើកិច្ចព្រមព្រៀង រវាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្តីពីការជំរុញ និងការការពារវិនិយោគ។ (**របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**)



២.៣- កិច្ចព្រមព្រៀងស្តីពីគយ

-អង្គប្រជុំបានឯកភាពលើទម្រង់ ខ្លឹមសារនៃកិច្ចព្រមព្រៀង ស្តីពីគយ។ (**អគ្គនាយកដ្ឋានគយ និងរដ្ឋាករ**)

អង្គប្រជុំត្រួតពិនិត្យចុងក្រោយ បានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងខាងលើនេះ នៅវេលាម៉ោង ១០:៤០ នាទី។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែមករា ឆ្នាំ២០១៤*



របាយការណ៍ស្ដីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំ**ខែមករា** ឆ្នាំ២០១៤នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី **០៦ ខែមីនា** ឆ្នាំ២០១៤ ដែលដឹកនាំដោយឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្ដូរប្រាក់

➡ នាខែមករាឆ្នាំ២០១៤ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,២% ធៀបនឹងខែមុន និងកើនឡើង ៤,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន(រយៈពេល១២ខែ)។ ក្រុមម្ហូបអាហារ សម្លៀកបំពាក់និងស្បែកជើង គ្រឿងសង្ហារឹម សុខាភិបាល ការកម្សាន្តនិងវប្បធម៌ ការសិក្សា និងភោជនីយដ្ឋាន ជាក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃកើនលើសពីអត្រាសរុប បើធៀបនឹងខែដូចគ្នាឆ្នាំមុន ។

| បើធៀបនឹងខែដូចគ្នាឆ្នាំមុនក្រុមទំនិញនិងមុខទំនិញសំខាន់ៗមានបម្រែបម្រួលថ្លៃដូចខាងក្រោម | | | |
|---|---|---|---|
| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
| ម្ហូបអាហារ : +៥,៧% | ការដឹកជញ្ជូន : −០,៧% | សាច់ជ្រូក : +៥,៥% | បន្លែ : +៤,៥% |
| សម្លៀកបំពាក់និងស្បែកជើង : +៦,០% | ទូរគមនាគមន៍ : −៣,០% | សាច់គោស្រស់ : +៩,១% | ឧស្ម័ន : +៥,៧% |
| ផ្ទះសំបែង ទឹក អគ្គិសនី...: +២,៧% | ការកម្សាន្តនិងវប្បធម៌ : +៥,៥% | សាច់មាន់ស្រស់ :+៧,១% | ប្រេងសាំង : -៥,០% |
| គ្រឿងសង្ហារិមនិងសម្ភារៈប្រើប្រាស់ : +៥,៧% | ការសិក្សា : +៨,៦% | ត្រីស្រស់ : +៦,៥% | ប្រេងម៉ាស៊ូត : -២,៤% |
| សុខាភិបាល : +៩,២% | ភោជនីយដ្ឋាន : +៧,២% | ផ្លែឈើ : +៨,៥% | |

តារាង១. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១២-២០១៤

| ឆ្នាំ | ធៀបនឹង... | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៤ | ខែដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៤,១% | ៤,៥% | | | | | | | | | |
| | ខែមុន | ០,២% | ០ | -០,៣% | ០,៩% | | | | | | | | | |
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,០% | ១,០% | ២,៨% | ២,៩% | ៤,០% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,០% |
| | ខែមុន | ០,៣% | ០,២% | -០,១% | ០,៦% | ០,៧% | ០,២% | ១% | ០,៤% | ០,៧% | ០,២% | -០,៣% | ០,៥% | |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| | ខែមុន | ១,០% | ០,៤% | ០,៦% | ០,៥% | -១,១% | ០,១% | ០% | ១,១% | ០,២% | -០,២% | -០,២% | ០% | |

**P:** តួលេខខែ កុម្ភៈ មីនា និងមេសា ឆ្នាំ២០១៤ ជាតួលេខព្យាករដោយក.ស.វ. (តាមវិធីសាស្ត្រ DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្ដប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន (ឆ្នាំ២០១២ ២០១៣ និង២០១៤)




➡**អត្រាប្តូរប្រាក់៖**

| *ប្រភេទ* | មករា២០១៤ | ធ្នូ២០១៣ | មករា២០១៣ | *ប្រភេទ* | មករា២០១៤ | ធ្នូ២០១៣ | មករា២០១៣ |
|---|---|---|---|---|---|---|---|
| រ/ដុល្លារ | ៣៩៩៥រ/១$ | ៣៩៩៥រ/១$ | ៣៩៩៥រ/១$ | បាត/ដុល្លារ | ៣៣,០១បាត/១$ | ៣២,៨៥បាត/១$ | ២៩,៧២បាត/១$ |
| រ/បាត | ១២១រ/១បាត | ១២២រ/១បាត | ១៣៤រ/១បាត | ដុង/ដុល្លារ | ២១០៣៥ដុង/១$ | ២១០៨០ដុង/១$ | ២០៨០៥ដុង/១$ |
| រ/ដុង | ០,១៩០រ/១ដុង | ០,១៩០រ/១ដុង | ០,១៩២រ/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់ធនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែមករា ឆ្នាំ២០១៤ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ៖** អនុវត្តបាន ៦៧០,៦ពាន់លានរៀល (មធ្យមប្រចាំខែ៧៩% នៃផែនការ) ក្នុងនោះចំណូលចរន្ត ៦៧០,៦ ពាន់លានរៀល (មធ្យមប្រចាំខែ ៨៣% នៃផែនការ) និងពុំមានចំណូលមូលធនទេ។

- បើធៀបនឹងខែមុន **ចំណូលថវិកាជាតិ** ថយចុះ៤៨% ប៉ុន្តែកើនឡើង២៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណូលចរន្ត ថយចុះ ៤៩% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ២៧% *ធៀបនឹងខែដូចគ្នាឆ្នាំមុន*។
- ក្នុងចំណូលចរន្ត៖

**ក្រាហ្វ ២. ចំណូលថវិកាជាតិ ឆ្នាំ ២០១២ — ២០១៤** (ពាន់លានរៀល)




- ✓ ចំណូលសារពើពន្ធមានចំនួន ៦៤៤,៤ពាន់លានរៀល ថយចុះ៣២% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៣៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។
- ✓ ចំណូលមិនមែនសារពើពន្ធមានចំនួន ២៦,២ពាន់លានរៀល ថយចុះ ៨៩% ធៀបនឹងខែមុន និងថយចុះ ៤៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

| បម្រែបម្រួលមុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ | | | បម្រែបម្រួលមុខចំណូលមួយចំនួនក្នុងចំណូលមិនមែនសារពើពន្ធ | | |
|---|---|---|---|---|---|
| | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន |
| ➢ ពន្ធ និងអាករគយ | ០ | +៣៣% | ➢ នេសាទ | +២៦៩% | +១២២១% |
| ➢ ចំណូលពន្ធដារ | -១៨% | +១០% | ➢ រុក្ខាប្រមាញ់ | -១០០% | — |
| ➢ ចំណូលសារពើពន្ធផ្សេងៗ | -៦៣% | -១១% | ➢ សម្បទានរ៉ែ | -៨៥% | -១៩% |
| ✧ កាស៊ីណូ | -៦៥% | -៧% | ➢ អាកាសចរណ៍ស៊ីវិល | -៦១% | -២៨% |
| ✧ អាជ្ញាបណ្ណក្នុងស្រុក | -៥៥% | -៤៥% | ➢ ផលទុននៃសកម្មភាពទេសចរណ៍ | -១០០% | -១០០% |
| ✧កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ | -៦១% | -១៣% | ➢ ប្រៃសណីយ៍ និងទូរគមនាគមន៍ | -៩៦% | -៩៣% |
| | | | ➢ អាករស្នាក់ទូត | -៤៧% | -៣% |
| | | | ➢ ការត្រួតពិនិត្យគុណភាពផលិតផល | -១០០% | -១០០% |

២.២. ***ចំណាយថវិកាជាតិ៖*** អនុវត្តបានចំនួន ២១៤ពាន់លានរៀល( *មធ្យមប្រចាំខែ ១៩% នៃផែនការ*) ក្នុងនោះ ចំណាយចរន្តមានចំនួន ២០៤ពាន់លានរៀល ( *មធ្យមប្រចាំខែ ៣០% នៃផែនការ*) និង**ចំណាយមូលធន**ចំនួន ១០ពាន់លានរៀល។

➢ *បើធៀបនឹងខែមុន* **ចំណាយថវិកាជាតិ** ថយចុះ ៧៣% ប៉ុន្តែកើនឡើង១២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ ចំណាយចរន្តថយចុះ ៦១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ១៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ រីឯ ចំណាយមូលធន ថយចុះ ៩៦% ធៀបនឹងខែមុន និង ថយចុះ៤៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ថវិកាជាតិនៃខែមករា មានអតិរេក ៤៥៦ ពាន់លានរៀល ស្មើនឹង ១១៤លានដុល្លារ ស.រ.អា។*

## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែមករា ឆ្នាំ២០១៤ មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុ $M_2$ មានចំនួន ៣៣២៩៥ពាន់លានរៀល កើនឡើង ១,៦%ធៀបនឹងខែមុន និងកើនឡើង ១៣,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ការកើនឡើងនៃ $M_2$ ធៀបនឹងខែមុន ជាចម្បងបណ្តាលមកពី ប្រាក់បញ្ញើចរន្តកើនឡើង១៥,៩% និងប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង១,៧%។

១៥,៩%និងប្រាក់បញ្ញើជារូបិយបណ្ណកើនឡើង១,៧%។

➢ ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន ១៧,៧% នៃរូបិយវត្ថុ $M_2$ និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨២,៣%។

ក្រាហ្វ៣. សមាសធាតុរូបិយវត្ថុខែមករា ឆ្នាំ២០១៤




| សមាមាត្រចំនួនប្រាក់រៀល ក្នុងរូបិយវត្ថុ $M_2$ | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| | ១៧,៧% | | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៤% | | | | | | | | | | | |

**បម្រែបម្រួលសមាសធាតុរូបិយវត្ថុ ក្នុងខែមករា ២០១៤៖ ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន**




➢ **ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៣៥១៥លានដុល្លារកើនឡើង ១,៦% ធៀបនឹងខែមុន និងកើនឡើង ១,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ៖*** ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ ក្នុងខែនេះមានចំនួន ១០៤៨៤ពាន់លានរៀល ស្ថិតនៅដដែលធៀបនឹងខែមុន ប៉ុន្តែកើនឡើង ៧,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ *ការផ្តល់ឥណទាន៖*

| *ផ្តល់ដោយ* | *មករា ២០១៤* | *ធ្នូ ២០១៣* | *មករា ២០១៣* |
|---|---|---|---|
| ធនាគារពាណិជ្ជ( ពាន់លានរៀល ) | ៣១៥៤៥ | ២៩៨៣៥ | ២៣៥៣០ |
| ក្នុងនោះ ជារៀល | — | ៤៣៦ | ៣៩៤ |
| គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ( ពាន់លានរៀល ) | — | ៥២៦២ | ៣៧១៦ |

➢ ***អត្រាការប្រាក់ប្រចាំឆ្នាំ*** នៅធនាគាពាណិជ្ជនាខែមករា៖

| ប្រភេទអត្រាការប្រាក់ | មករា២០១៤ | ធ្នូ២០១៣ | មករា២០១៣ |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | — | ៥,៨០% | ៥,៩៤% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៥,៧០% | ១៥,៧២% | ១១,៧៨% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៦៧% | ៤,២៧% | ៤,៤៥% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៤៩% | ១១,៣៥% | ១១,៨៥% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែមករាឆ្នាំ២០១៤ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢ **កសិកម្ម៖**

✓ផលិតផលនេសាទមាន ៩៥ ពាន់តោន កើនឡើង ១% ធៀបនឹងខែមុន និងកើនឡើង ៥៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ **ឧស្សាហកម្ម៖**

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ២៨៣ GWh ថយចុះ ៨% ធៀបនឹងខែមុន ប៉ុន្តែស្ថិតនៅថេរ ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះវារីអគ្គិសនីមានចំនួន ៦៤,៤ GWh ថយចុះ ១% ធៀបនឹងខែមុនប៉ុន្តែកើនឡើង ៤០០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៤០៣ លានដុល្លារថយចុះ ២% ធៀបនឹងខែមុន និងថយចុះ ៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

✓ ការចុះបញ្ជីរោងចក្រឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម៖

| ប្រភេទ | ចំនួន — មករា២០១៤ | ចំនួន—ធ្នូ២០១៣ | ចំនួន—មករា២០១៣ |
|---|---|---|---|
| រោងចក្រថ្មីដែលបានចុះបញ្ជី | | ៣៩ | ១៥ |
| ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | | ១១១៩ | ៩២៣ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | ៣៥ | ១០ |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | ៣៧ | ១៤ |

➢ **សំណង់** (ការអនុញ្ញាត)៖

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១៤៧៦,១ពាន់ម៉$^2$ កើនឡើង ១៣១% ធៀបនឹងខែមុន និងកើនឡើង២៥២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៥៨៤,៥លានដុល្លារ កើនឡើង ២៤០% ធៀបនឹងខែមុន និង កើនឡើង ៣៦៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

| ប្រភេទ | ពាន់ម៉$^2$ —មករា២០១៤ | ពាន់ម៉$^2$ —ធ្នូ២០១៣ | ពាន់ម៉$^2$ —មករា ២០១៣ |
|---|---|---|---|
| ▪ លំនៅឋាន | ៧៧៨,៧ | ៨៩,១ | ១៤៤,២ |
| ▪ ពាណិជ្ជកម្ម | ៦២៧,៩ | ១,២ | ១៣៨,៧ |
| … | | | |
| អនុញ្ញាតសរុប | ១៤៧៦,១ | ៦៣៩,៧ | ៤១៩,៨ |

✓ ដូច្នេះ សំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ លំនៅឋាន៥៣% និងឧស្សាហកម្ម ៤៣% នៃផ្ទៃក្រឡាសរុប ។

➢ **ការងារ៖**

| ប្រភេទ | នាក់ : មករា២០១៤ | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | | | |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ២៥៩៣ | +៤% | -១៨% |
| អ្នកទទួលបានការងារក្នុងប្រទេស | ១៥៧៧ | +១៨% | +១៩% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១០១៦ | -១៣% | -៤៥% |

- **វិនិយោគ៖**

✓គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក. និង គ.ស.ព. (ថ្មីនិងពង្រីក)៖

| ប្រភេទ | មករា២០១៤ | ធ្នូ២០១៣ | មករា២០១៣ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ១០៦,៣ | ៥៨០,៨ | ៦៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៣,៥ | ៣៦១,៤ | ០ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខតំបន់សេដ្ឋកិច្ចពិសេស) | ១០២,៨ (១៨) | ១៨១,៨ (៥៧,៣) | ៦៣ (៩) |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ៤៧,៦ | ០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ២៤ | ៤៦ | ១៤ |
| បង្កើតការងារ (ពាន់នាក់) | ២៨,៧ | ៧៦,៩ | ២៦ |

- **សេវាកម្ម និងទេសចរណ៍៖**

✓ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—មករា២០១៤ | ចំនួន—ធ្នូ២០១៣ | ចំនួន—មករា២០១៣ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៣៩៥ | ២៩៩ | ១៥៣ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៣ | ៣ | ៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | ? | ២៦៣ | ១៣០ |

✓**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប ៥កំពង់ផែ) មានចំនួន ១៥៨៨,៧ពាន់តោន កើនឡើង ១១៩% ធៀបនឹងខែមុន និងកើនឡើង ២៣៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ក្នុងវង់ក្រចក : បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ : +១៨% | (+៣៦%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង : +១៤% | (+២៨៩%) |
| ▪ កំពង់ផែកំពង់សោម : +២៧៣% | (+៣៦១%) | ▪ កំពង់ផែឧកញ៉ាម៉ុង : -៤% | (+១៤៧%) |

✓**ការធ្វើដំណើរតាមផ្លូវអាកាស និងទេសចរណ៍៖**

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១០.០ | -៣៦% | -១០% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២៦,១ | +៤% | +២៧% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៥៥៩,៥ | +១២% | +១៥% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ៦៩ | -៥% | -៤% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤៤២ | +២% | +៩% |
| ✓ តាមផ្លូវអាកាស | ២៥៤ | +១២% | +១៨% |
| ✓ តាមផ្លូវគោក និងទឹក | ១៨៨ | -៨% | ០ |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលខែមករាមានចំនួន ៣១៤៩ពាន់លានរៀល (៧៨៧លានដុល្លារ) ថយចុះ ២០% ធៀបនឹងខែមុន និងថយចុះ ៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | +១០% | +១៤% | រថយន្តសរុប (ព.ល.រ) | +១៨% | +២០% |
| ប្រេងម៉ាស៊ូត | +៩% | -៩% | រថយន្តសរុប (គ្រឿង) | +៥% | ០ |
| ឧស្ម័ន | +៦% | +២៨% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | +១៤% | +២០% |

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| អគ្គិសនីនាំចូល | +១% | -៨% | ម៉ូតូ (គ្រឿង) | -២៣% | +២៥% |
| ដែកសំណង់ | +១០% | -៣% | អង្ករ | +១៨% | -៩០% |
| ស៊ីម៉ង់ត៍ | -៥% | +៤៦% | ផ្លែឈើនិងបន្លែ | +២% | +២៦០% |
| គ្រឿងអេឡិចត្រូនិក | -២៥% | +១៨៣% | ជីនិងថ្នាំកសិកម្ម | -២៩% | +៥៤% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -១២% | +៤% |

➡ **ការនាំចេញ**ខែមករាឆ្នាំ២០១៤ មានចំនួន ២៧១៥ពាន់លានរៀល ស្មើនឹង៦៧៨,៧លានដុល្លារ ស.រ.អា. (៨៦% នៃការនាំចូល) កើនឡើង ២% ធៀបនឹងខែមុន និងកើនឡើង ១៧% ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះមុខទំនិញសំខាន់ៗមាន៖

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -២១% | +២០៧% | ផលិតផលនេសាទ | -៣៥% | +៦៨% |
| វាយនភណ្ឌនិងស្បែកជើង | +១២% | +១២% | កៅស៊ូ | -៣២% | +២២% |
| អង្ករ | -៤៦% | -១៨% | | | |

➡ក្នុងខែមករានេះ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៤៣៥ពាន់លានរៀល ស្មើនឹង ១០៩លានដុល្លារ ស.រ.អា.។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែមករា ឆ្នាំ២០១៤នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ចំណូលមិនមែនសារពើពន្ធ | -៨៩% | -៤៧% | — |
| ២ | អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | 0% | +៣៣% | កើនពី ១១,៨% (មករា២០១៣) ទៅ ១៥,៧% (មករា២០១៤) |
| ៣ | ការនាំចូលផ្លែឈើ និងបន្លែ | +២% | +២៦០% | — |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) អតិផរណាខែមករា ឆ្នាំ២០១៤ ស្មើនឹង ៤,៥% (គឺកំណើនសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ធៀបនឹងខែដូចគ្នាឆ្នាំមុន) ជាអត្រាប្រហាក់ប្រហែលនឹងផែនការគោលនយោបាយ ៥%។ ក្រុមទំនិញដែលមានការរួមចំណែកគួរឲ្យកត់សម្គាល់គឺ សាច់ ត្រី ផ្លែឈើ បន្លែ និងសុខាភិបាល។

២) ចំណាយថវិកាជាតិនាដើមឆ្នាំតែងតែមានការយឺតយ៉ាវ ។ ក្នុងខែមករានេះ ចំណាយថវិកាជាតិមានកម្រិតតែ ៣២% នៃចំណូលថវិការប៉ុណ្ណោះ។

៣) យោងតាមសូចនាកររូបិយវត្ថុ ប្រាក់រៀលក្រៅធនាគារមានចំនួនតិច ដែលធ្វើឲ្យប្រាក់រៀលមានការឡើងថ្លៃ និងកម្រិតដុល្លារូបនីយកម្មនៃសេដ្ឋកិច្ចកម្ពុជាមានការកើនឡើង។

៤) គួរកត់សម្គាល់ថា តួលេខវិនិយោគ និងសំណង់ក្នុងខែទី១ ដើមឆ្នាំ២០១៤ មានការកើនឡើងធៀបនឹងខែដូចគ្នាឆ្នាំមុន។

៥) មានសំណើសុំបញ្ចូលតួលេខអគ្គិសនីដើរដោយធ្យូងថ្មក្នុងតារាងវិភាគ។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០២/១៤ ម៉ោង ១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយផ្នែកគណនេយ្យ ECOSOCC នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ២ | ១១/០២/១៤ ម៉ោង ១១:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក **អ៊ិត សារ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្ដីការ គណៈរដ្ឋមន្ត្រី។ |
| ៣ | ១២/០២/១៤ ម៉ោង ១៦:០០នាទី | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ១៣/០២/១៤ ម៉ោង០៧:៣០នាទី | ដឹកនាំគណៈប្រតិភូក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ទៅទស្សនកិច្ចតំបន់អភិវឌ្ឍន៍កសិកម្មមួយកន្លែង នៅខេត្តកណ្ដាល។ |
| ៥ | ១៦/០២/១៤ ម៉ោង ១៨:០០នាទី | ចូលរួមជាអធិបតី ក្នុងពិធីជប់លៀងទទួលគណៈប្រតិភូគណៈមេធាវីមកពីប្រទេស បារាំង នៅរាជធានីភ្នំពេញ។ |
| ៦ | ១៧/០២/១៤ ម៉ោង ១៩:០០នាទី | ចូលរួមក្នុងពិធីជប់លៀងជូនគណៈប្រតិភូគណៈមេធាវីមកពីប្រទេសបារាំង ដែលរៀបចំដោយស្ថានទូតបារាំង នៅស្ថានទូតបារាំង។ |
| ៧ | ១៨/០២/១៤ ម៉ោង ១៩:០០នាទី | ចូលរួមក្នុងពិធីជប់លៀងដែលរៀបចំដោយគណៈប្រតិភូគណៈមេធាវីមកពីប្រទេសបារាំង នៅរាជធានីភ្នំពេញ។ |
| ៨ | ១៩/០២/១៤ ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖ ១-សេចក្ដីព្រាងគោលនយោបាយជាតិស្ដីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។ ២-សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កកទ្រព្យសម្បត្តិរបស់ភេរវករ និងអង្គការនានា។ ៣-បញ្ហាផ្សេងៗ។ ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ២០/០២/១៤ ម៉ោង ០៨:០០នាទី | ចូលរួមជាអធិបតី ក្នុងកិច្ចប្រជុំផ្សព្វផ្សាយអំពីការកំណត់តំបន់សន្តិសុខ និងតំបន់សុវត្ថិភាពជុំវិញបរិវេណ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅសាលប្រជុំសាលាខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ |
| ១០ | ២០/០២/១៤ ម៉ោង ១៥:៣០នាទី | ចូលរួមជាអធិបតី ក្នុងកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅទីស្ដីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១១ | **២១/០២/១៤** **ម៉ោង ០៨:៣០នាទី** | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីសុវត្ថិភាពចរាចរណ៍ផ្លូវគោក។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កកទ្រព្យសម្បត្តិរបស់ភេរវករនិងអង្គការនានា។<br>៣-បញ្ហាផ្សេងៗ៖ សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំសច្ចាប័នពីស្ថាប័ននីតិប្បញ្ញត្តិ លើ៖<br>៣.១-កិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និង ពិធីសារ នៃធម្មនុញ្ញអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះ។<br>៣.២-ពិធីសារស្តីពីវិសោធនកម្មលើកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការជំរុញនិងការការពារ វិនិយោគ។<br>៣.៣-កិច្ចព្រមព្រៀងអាស៊ានស្តីពីគយ។<br>៣.៤-លិខិតសន្យាទូទាត់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ឱ្យក្រុមហ៊ុន ស៊ីធីលុម អេសអេ (CITELUM S.A) សម្រាប់គម្រោងវិនិយោគសាងសង់ ផ្ទេរ និងធ្វើ ប្រតិបត្តិការ (BTOC) អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសេវាបំភ្លឺសាធារណៈនៅរាជធានី ភ្នំពេញ។<br>នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១២ | **២១/០២/១៤** **ម៉ោង ១៥:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីការរៀបចំអង្គការតុលាការ។<br>២-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | **២៤/០២/១៤** **ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៣ និងផែនការសកម្មភាពការងារ ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៤ | **២៥/០២/១៤** **ម៉ោង ១០:៣០នាទី** | ចូលរួមជាសមាជិក ក្នុងពិធីសម្ពោធការថតខ្សែភាពយន្តភាគរឿង "**ឥទ្ធិពលនៃស្នេហ៍**" នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង **លោក ជំទាវ** នៅសណ្ឋាគារណាហ្គាវើល។ |

# ព្រឹត្តិបត្រព័ត៌មាន

| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម  គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ង៉ាន់ ភិរុណ | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង វត្ថមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ធារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត កក្កដា | មន្ត្រី ក.ស.វ. |



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in